ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ:..................អគ.

# សេចក្តីប្រកាសព័ត៌មាន

ក្នុងនាមព្រះរាជាណាចក្រកម្ពុជាដែលជាសមាជិកនៃវេទិកាអាស៊ី- អឺរ៉ុប (ASEM) អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានចូលរួមក្នុងគម្រោងប្រតិបត្តិការគយរួមគ្នា ដែលមានឈ្មោះថា “Joint Customs Operation DIABOLO II” ឬ “DIABOLO II” ស្របតាមសេចក្តីសម្រេចរបស់កិច្ចប្រជុំ ASEM នៅប្រទេសជប៉ុនឆ្នាំ ២០០៧ កិច្ចប្រជុំ ASEM Working Group (AWG) លើកទី១នៅប្រទេសបារាំងឆ្នាំ២០០៨ និងកិច្ចប្រជុំ AWG លើកទី៣នៅប្រទេសហុងគ្រីឆ្នាំ២០០៩។ ប្រទេសចូលរួមក្នុងគម្រោងនេះ មានប្រទេសអឺរ៉ុបចំនួន ២៧ និងប្រទេសអាស៊ីចំនួន ១៣ ដែលក្នុងនោះមាន ព្រះរាជាណាចក្រកម្ពុជាផងដែរ និងរួមទាំងលេខាធិការដ្ឋានអាស៊ាន និង European Commission។ គម្រោងនេះត្រូវបានអនុវត្តចាប់ពីខែសីហាដល់ខែតុលាឆ្នាំ២០០៩។ ការវាយតម្លៃលទ្ធផលនៃការអនុវត្តគម្រោងនេះ ត្រូវបានធ្វើនៅប្រទេសជប៉ុនកាលពីខែមករា ឆ្នាំ២០១០កន្លងមកនេះ។ គោលបំណងជាសំខាន់និងជាយុទ្ធសាស្ត្រគឺការទប់ស្កាត់និងបង្ក្រាប លើពាណិជ្ជកម្មខុសច្បាប់និងការរត់ពន្ធបារីនិងថ្នាំជក់ (Illegal/Illegitimate trade and smuggling of cigarettes and tobacco) និងពាណិជ្ជកម្មបារីក្លែងក្លាយ (Trade on counterfeit cigarettes) ដែលនាំចេញពីបណ្តាកំពង់ផែអាស៊ីទៅកាន់បណ្តាកំពង់ផែសហគមន៍អឺរ៉ុប។

ជាលទ្ធផល អង្គភាពគយបង្ក្រាបបារីក្លែងក្លាយបានជាង៦៥លានដើមបារី និងផលិតផលក្លែងក្លាយផ្សេងទៀតដូច ជាស្បែកជើង ម៉ាស៊ីនថត ទូរស័ព្ទដៃ។ល។ ចំនួនជាង៣៦០ 000 ផងដែរ។ លទ្ធផលនេះ បានមកពីការកំណត់និងវាយតម្លៃហានិភ័យលើ Container ប្រមាណជាង ៣០០គ្រឿង និងត្រួតពិនិត្យរូបវន្តលើ Container ទាំងនោះប្រមាណ៣០គ្រឿង។ យោងប្រភពអង្គភាពអនុវត្តច្បាប់របស់សហគមន៍អឺរ៉ុប (Europol) និង ស្ថាប័ននគរបាលអន្តរជាតិ (Interpol) បុគ្គលឬក្រុមហ៊ុនប្រមាណ ៨៩ ដែលជាប់ពាក់ព័ន្ធ កំពុងត្រូវបានកំណត់ដើម្បីស៊ើបអង្កេត។ សកម្មភាពខុសច្បាប់ខាងលើបាននាំអោយ ខាតបង់ចំណូលថវិការដ្ឋយ៉ាងធំធេង ប៉ះពាល់ដល់ធុរៈកិច្ចរបស់ផលិតករនិងពាណិជ្ជករសុចរិត ប៉ះពាល់បរិយាកាសប្រកួត ប្រជែងតាមបែបទីផ្សារសេរី ខូចខាតប្រយោជន៍សេដ្ឋកិច្ចពាក់ព័ន្ធនានា និងមានផលវិបាកជាអវិជ្ជមានខាងសុខភាពអ្នកប្រើប្រាស់។

ក្នុងបរិបទដូចខាងលើនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សូមអំពាវនាវដល់ក្រសួង- ស្ថាប័នរាជការសាធារណៈ អង្គការ- សង្គមស៊ីវិល បុគ្គលសាធារណៈនិងឯកជន សហគមន៍ធុរៈកិច្ចនានា ចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពខុសច្បាប់ អោយមានប្រសិទ្ធិភាពនិងទទួលបានជោគជ័យធំធេងថ្មីទៀត ក្នុងបុព្វហេតុអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកម្ពុជាឆ្ពោះទៅកាន់ភាពរុងរឿង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ មិនា ឆ្នាំ ២០១០ ។